ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណេងឡើយ ។

* * *

ប្រកាសលេខ ១៣២ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ព ច័ន្ទនី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៨៦៦៩ ក.ណ ចុះថ្ងៃទី ១៦-០១-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ព្រែកថ្មី ឃុំ ព្រែកថ្មី ស្រុកកោះធំ ខេត្ត កណ្តាល បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើមនៅក្នុងទីតាំង ភូមិ ព្រែកថ្មី ឃុំព្រែកថ្មី ស្រុក កោះធំ ខេត្ត កណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណេងឡើយ ។

* * *

ប្រកាសលេខ ១៣៣ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **គៀវ ម្នា** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១០៤៣៨០ ក.ព ចុះថ្ងៃទី ២៥-៤-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦១ ផ្លូវជាតិលេខ ២ សង្កាត់ ចាក់អង្រែលើ ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មផលិតឥដ្ឋ ក្បឿង នៅក្នុងទីតាំង ភូមិ ថ្មី ឃុំ កំពង់ប្រណាក ស្រុក ត្បែងមានជ័យ ខេត្តព្រះវិហារ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៣៤ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ ឌី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១២១៨៥ ប.ប ចុះថ្ងៃទី ២០-០១-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣៧ ភូមិ ១៣ មករា ថ្មី ឃុំ ព្រែកព្រះស្តេច ស្វាយប៉ោ ខេត្ត បាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ភូមិ កោះរាម ឃុំ ខ្នាចរមាស ស្រុក បវេល ខេត្ត បាត់ ដំបង ។

ប្រការ ២ : លោក **សុខ ឌី** ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានាទូវទិន្នអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៣៥ ផក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៨៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ នី** ជនជាតិ ខ្មែរ កម្ពុជា សញ្ជាតិ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១២១៨៥ ប.ប ចុះថ្ងៃទី ២០-០១-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣៧ ភូមិ ១៣ ឃុំ មករា ថ្មី ឃុំ ព្រែកព្រះស្តេច ស្រុក ស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីន កិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំង ភូមិខ្នាចរមាស ឃុំ ខ្នាចរមាស ស្រុក បវេល ខេត្ត បាត់ដំបង ។

ប្រការ ២ : លោក **សុខ នី** ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ១ដោយធានានូវទិន្នផលអង្ករលេខ១អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយសំណងឡើយ ។

* * *

ប្រកាសលេខ ១៣៦ ផក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៨៧

ប្រការ ១ : អនុញ្ញាតអោយលោក **នាយ ម៉ុន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣០៥៣៦ ប.ប ចុះថ្ងៃទី ០៩-៨-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិចុងព្រែក ឃុំ ក្តុល ស្រុក ស្វាយប៉ោ ខេត្ត បាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំងភូមិ ចុងព្រែក ឃុំ ក្តុល ស្រុកស្វាយ ប៉ោ ខេត្ត បាត់ដំបង ។

ប្រការ ២ : លោក **ខាយ ម៉ុន** ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៣៧ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈុំ សេងលី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ១០៨៦៨៧ ក.ណ ចុះថ្ងៃទី ១៥–៩–៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ព្រែកតាបែន ឃុំ ព្រះប្រសប់ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកក ដើមនៅក្នុងទីតាំង ភូមិ ព្រែកថ្មី ឃុំ ព្រែកអញ្ចាញ ស្រុក មុខកំពូល ខេត្ត កណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៣៨ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **តាំង ហៀង** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៤១២៩ ភ.ព ចុះថ្ងៃទី ០៤–៣–៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២១៨៤ ផ្លូវលេខ ៧២ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

បន្តដំណើរការរោងម៉ាស៊ីន ផលិតទឹកកកដើម នៅក្នុងទីតាំងភូមិ ស្វាយតាមេឃ ឃុំកោះធំ "ខ" ស្រុក កោះធំ ខេត្ត កណ្ដាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យស្នើសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៣៩ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ទិត សុខ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៩៥០៧ ប.ប ចុះថ្ងៃទី ២៥–០៧–៩០ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២៧ ភូមិ ហៃសានជ្រៃ ឃុំ ជ្រៃ ស្រុក បាត់ដំបង ខេត្ត បាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ទិត សុខ** ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៤០ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សុខ ម៉ុំ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៣៧៣៩០ ប.ប ចុះថ្ងៃទី ១២–១២–៨៨ អាស័យដ្ឋានបច្ចុប្បន្ន

ក្រុមទី ១៥ ភូមិ ស្វាយជ្រំ ឃុំជ្រៃ ស្រុក បាត់ដំបង ខេត្ត បាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **សុខ មុំ** ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ១៤១ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សុខ សាខរិន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០២៩៧០៤ ភ.ព ចុះថ្ងៃទី ០៣–០១–៨៥ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ៩ ភូមិ ទី ២ ឃុំ ដងទង់ ស្រុក ស្មាច់មានជ័យ ខេត្ត កោះកុង បន្តដំណើរការសិប្បកម្មផលិតស្រាកែច្នៃ " ស្រាសកោះកុង " នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **សុខ សាខរិន** ត្រូវបានអនុញ្ញាតអោយបន្តដំណើរការផលិតកម្ម អាជីវកម្មដោយផលិតនូវមុខផលិតផលស្រាកែច្នៃ " ស្រាសកោះកុង " សញ្ញាសំគាល់ " ខ្យងសមុទ្រ " ស្របតាមគំរូសញ្ញាសំគាល់ ដែលបានដាក់តំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ុត ទ្រាំង

៣_ និស្ថិការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៣៤/៩៧ ពម.ប្រក

រដ្ឋមន្ត្រីក្រសួងពត៌មាន

–បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញ ច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន ចុះថ្ងៃទី ៣៤–០១–១៩៩៦

–ពិនិត្យលើសំណើសុំអនុញ្ញាតច្បាប់បើកអាជីវកម្ម ទូរទស្សន៍ខ្សែកាបរបស់លោក ឡាយ គង់សាវុធ ចុះថ្ងៃទី ១២–១២–១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ឡាយ គង់សាវុធ** បច្ចុប្បន្នស្ថិតនៅផ្ទះលេខ ៧១៣ អឺ០ ក្រុម ទី ១៦ ផ្លូវ ព្រះមុនីវង្ស សង្កាត់បឹងកេងកងទី៣ ខ័ណ្ឌចំការមន រាជធានី

ភ្នំពេញបើកទូរទស្សន៍ខ្មែរកាបឈ្មោះ " ពន្លឺថ្លាយ " សំរាប់បន្តជាវអោយអតិថិជន នៅទីក្រុង ព្រះសីហនុ ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ទូរទស្សន៍ខ្មែរកាប ត្រូវគោរពតាមកិច្ចសន្យា និង ច្បាប់បញ្ញត្តិបទបញ្ជា ឬ សេចក្តីណែនាំខាងផ្នែកសោតទស្សន៍ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជាព្រមទាំងមូទួលការណែនាំផ្ទាល់ពី មន្ទីរពត៌មានក្រុងព្រះសីហនុ ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចចែងក្នុងប្រការទី ២ សាមីខ្លួននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការចោះពុម្ពផ្សាយ សោតទស្សន៍ នៃក្រសួងពត៌មាន មន្ទីរពត៌មានក្រុងព្រះសីហនុ សាមីខ្លួន និង អាជ្ញាធរដែលពាក់ព័ន្ធត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៣៥/ ៩៧ ពម.ប្រក

ស្តីពីការតែងតាំង មន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រម នស.រកម ០១៩៦–១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការប្រកាសអោយឃើញច្បាប់បង្កើតក្រសួងពតិមាន
- បានឃើញលិខិតលេខ ៣១៤៨ ខបម.កប ចុះថ្ងៃទី ១៣ ខែ មករា ១៩៩៧ របស់អភិបាលខេត្តបាត់ដំបង
- បានឃើញលិខិតលេខ ៣១៤៨ ខបម.កប ចុះថ្ងៃទី ១៣ ខែ មករា ១៩៩៧ របស់អភិបាលខេត្តបាត់ដំបង
- ពិនិត្យលើសលក្ខណៈសម្បត្តិនិងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **អេ. សោភ** ជាប្រធានមន្ទីរពតិមាន ខេត្តបាត់ដំបង នៃ ក្រសួងពតិមាន ។

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ បណ្ដាអគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យហិរញ្ញវត្ថុមន្ទីរពតិមានខេត្តបាត់ដំបង គ្រប់មន្ទីរពតិមានខេត្ត ក្រុង និងសាមីខ្លួនត្រូវអនុវត្តប្រកាស នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៣៧/៩៧ ពម .ប្រក

អនុញ្ញាតិអោយប្ដូរឈ្មោះកាសែត « ខ្មែរអង្គរ »

មកឈ្មោះ «សម្លេងប្រជាជនខ្មែរ »

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស រកម ០៨៩៥ ចុះថ្ងៃទី ០១ ខែកញ្ញា ១៩៩៥ ។

-បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ១៩៨/៩៥ ពម.ប្រក ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការអនុញ្ញាតអោយកាសែត"ខ្មែរអង្គរ "បោះពុម្ពចេញផ្សាយដោយមានលោក សាយ យាង ជាចាងហ្វាងការផ្សាយ ។

-បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ១៨៣/៩៥ ពម.ប្រក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីកាផ្ទេរឋានៈចាងហ្វាងការផ្សាយកាសែត "ខ្មែរអង្គរ"ពីលោក សាយ យាង ជូនទៅលោក កែវ ប្រាក់សុវណ្ណពេជ្រមុនិរត្ន វិញ ។

-បានឃើញសំណើសុំប្តូរឈ្មោះកាសែត "ខ្មែរអង្គរ"មក "សម្លេងប្រជាជនខ្មែរ"របស់ លោកកែវប្រាក់សុវណ្ណមុនីរត្ន ហៅព្រំ ម៉ុយ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះកាសែត "ខ្មែរអង្គរ"មកឈ្មោះ"សម្លេងប្រជាជនខ្មែរ"វិញ ដោយមានលោក កែវ ប្រាក់សុវណ្ណ ពេជ្រមុនីរត្នហៅ ព្រំ ម៉ុយជាចាងហ្វាង ការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៨៣ ផ្លូវលេខ ១៩០ សង្កាត់ផ្សារដេប៉ូទី ២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណនៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ៥ថ្ងៃមកក្រសួងពត៌មានដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : ប្រកាសលេខ ១៩៨/៩៥ ពម.ប្រក ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការអនុញ្ញាតអោយកាសែត "ខ្មែរអង្គរ "ចេញផ្សាយនិងប្រកាសលេខ ១៨៣/៩៥

ពម.ប្រក ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ១៩៩៥ របស់ក្រសួងពត៌មានស្តីពីការផ្ទេរឋានៈចាងហ្វាងការផ្សាយកាសែត "ខ្មែរអង្គរ" ពីលោក សាយ ឃាង ជូនទៅលោក កែវ ប្រាក់សុវណ្ណពេជ្រមុនីវង្ស វិញទុកជានិរាករណ៍ ។

ប្រការ ៣ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រម សីលធម៌អ្នកកាសែត ច្បាប់ស្តីពីរបបសារពត៌មាននិងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួចត្រូវប្រគល់កាសែតចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : ក្នុងករណីប្រព្រឹត្តល្មើស និងសេចក្តីដូចមានចែង ក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួន ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមជ្ឈមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង ចាងហ្វាងកាសែត "សម្លេងប្រជាជន" ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣៩/៩៧ ពម.ប្រក
អនុញ្ញាតអោយលោក សួន ហុងស៊្រុន បើក
អាជីវកម្មរោងពុម្ពឈ្មោះ « សួនវឌ្ឍនៈ »
រដ្ឋមន្ត្រីក្រសួងពត៌មាន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-យោងលិខិតជូនដំណឹង របស់ក្រសួងពត៌មាន លេខ ១.២២៤/៩៤ ពម ចុះ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ ។

-យោងលិខិតសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ពឈ្មោះ "សួនវឌ្ឍនៈ" របស់លោក សួន ហុងស្រ៊ុន ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **សួន ហុងស្រ៊ុន** ស្ថិតនៅផ្ទះលេខ ៣៤៥ សង្កាត់ បឹងកក់ ១ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ"សួនវឌ្ឍនៈ" ដែលមានទីតាំងស្ថិតនៅនៅលំនៅស្ថានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របតាមទំនៀមទំលាប់សន្តិសុខសណ្តាប់ធ្នាប់សង្គម និង និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋាន គ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៣៩/៩៧ ពម.ប្រក

អនុញ្ញាតអោយលោក Kenneth Nelson Cramer

នាំចូលសៀវភៅបំភ្លឺអ្នកទេសចរ ជាភាសាអង់គ្លេស

ប្រកាស

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១ ។

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

–បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

–បានឃើញសំណើសុំរបស់លោក kenneth Nelson Cramer ចុះថ្ងៃទី ៣ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការស្នើនាំចូលសៀវភៅបំភ្លឺអ្នកទេសចរឈ្មោះ The Sihanouk ville Visitor's Guide ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក kenneth Nelson Cramer សញ្ជាតិអាមេរិកាំងនាំចូលសៀវភៅបំភ្លឺអ្នកទេសចរជាភាសាអង់គ្លេសឈ្មោះ The Sihanouk ville Visitor's Guide ចូលមកព្រះរាជាណាចក្រកម្ពុជា ដើម្បីចែកផ្សាយដោយឥតគិតថ្លៃ ។ សៀវភៅនេះមានទីស្នាក់ការនៅក្រុងព្រះសីហនុ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចមួយដែលផ្ទុយនឹង ប្រកាសនេះត្រូវជូនដំណឹងក្រសួងពត៌មានជាមុន ០៥ ថ្ងៃ ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយនាំចូលត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្តីពីរបបសារពត៌មាននិងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់សៀវភៅចំនួន ០៦ ក្បាល រៀងរាល់លេខនាំចូលមកទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស អំពីសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង ចាងហ្វាងការផ្សាយសៀវភៅ The Sihanou k ville Visitor's Guide ជាភាសាអង់គ្លេសត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាព រយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៦២/៩៧ ពម.ប្រក
អនុញ្ញាតអោយលោក ហ៊ុល គន្ធលទរ៉ា នាំចូល
ទស្សនាវដ្តីជាភាសាខ្មែរ និង ភាសាអង់គ្លេសឈ្មោះ «សួស្តី »

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាជំពូក ៣ មាត្រាទី ៤១

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតាំងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

–បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

–បានឃើញសំណើសុំរបស់លោក ហ៊ុយ កន្ធុលរ៉ា ចុះថ្ងៃទី ៣០ តុលា ឆ្នាំ ១៩៩៦ ស្តីពីការស្នើនាំចូលទស្សនាវដ្តីឈ្មោះ "សួស្តី" មកចូលព្រះរាជាណាចក្រកម្ពុជា ។

សំរេច

ប្រការ ១ : អនុញ្ញាតិអោយលោក **ហ៊ុយ កន្ធុលរ៉ា** សញ្ជាតិ អាមេរិក នាំចូលទស្សនាវដ្តីជាភាសាខ្មែរ និងភាសាអង់គ្លេសឈ្មោះ "សួស្តី" ចូលមកព្រះរាជាណាចក្រកម្ពុជា ដោយមានរូបលោកផ្ទាល់ជាអ្នកទទួលខុសត្រូវ ។ ទីស្នាក់ការផ្ទះលេខ ៣២៨ ផ្លូវម៉ៅសេទុង សង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយដែលផ្ទុយនឹងប្រកាសនេះត្រូវជូនដំណើង មកក្រសួងពត៌មានជាមុន ០៥ ថ្ងៃ ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើការបោះពុម្ពចែកផ្សាយនាំចូលត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្តីពីរបបសារពត៌មាននិងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ទស្សនាវដ្តីចំនួន ០៦ ច្បាប់ រៀងរាល់លេខនាំចូលមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស អំពីសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះសាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាងការផ្សាយទស្សនាវដ្តី "សួស្តី" ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាព រយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ ភាញូរិទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៦៣/៩៧ ពម.ប្រក
ស្តីពីការតែងតាំង មន្ត្រីរាជការ

****

រដ្ឋមន្ត្រីក្រសួងពត៌មាន

–បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

–បានឃើញ ព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី

–បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពិតមាន

–បានឃើញចំណោរឯកភាពរបស់ឯកឧត្តមអភិបាលខេត្តក្រចេះលេខ ៣៤ ចណ.ក្រច ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

–យោងតាមការចាំបាច់

–ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន០២ នាក់ថ្នាក់ប្រធានមន្ទីរ និងអនុប្រធានមន្ទីរពតិមាន ខេត្តក្រចេះ នៃក្រសួងពតិមានដូចមានរាយនាមខាងក្រោមនេះ ។

១–លោក គីម បាត ជាប្រធានមន្ទីរពតិមាន

២–លោក អ៊ុក ច្រឹង ជាអនុប្រធានមន្ទីរពតិមាន

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ បណ្ណោអគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យហិរញ្ញវត្ថុ គ្រប់មន្ទីរពតិមានខេត្តក្រុង និង សាម៉ីខ្លួនត្រូវអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៤–ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១០០ ប្រក.សក.ប

ស្តីពីការផ្ទេរមន្ត្រី រាជការ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

–បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤/៩០ ចុះថ្ងៃទី ៣១.១០.១៩៩៤ ស្តីពីកាកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦.០៣ ចុះថ្ងៃទី២៤.០១. ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន ។

-បានឃើញ ប្រកាសលេខ ៤៦៧/បក.សកប ចុះថ្ងៃទី ០៣.៧.១៩៩៥

-យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : លោក **សុខុម [illegible]** អនុប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនក្រុងព្រះសីហនុ ត្រូវបានផ្ទេរអោយមកទទួលបន្ទុកជានាយករងនៃរាជាយស្វ័យយានកម្ពុជា ។

ប្រការ ២ : លោកនាយកខុទ្ទកាល័យ ក្រសួងសាធារណការនិងដឹកជញ្ជូន លោកនាយករាជាយស្វ័យយានកម្ពុជា និង លោកប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនក្រុងព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តន៍រៀងៗ ខ្លួនតាមខ្លឹមសារនៃប្រកាសនេះ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ហត្ថលេខា និង ត្រា

អ៊ឹង គៀត

* * *

៥_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣៦ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ក្បាលកោះសូទិន មកជា

សាលាបឋមសិក្សា ឈើន គឹមយោគ ក្បាលកោះសូទិន

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

–បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

–បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

–បានឃើញ ព្រះរាជក្រឹត្យលេខ សន.រកត.០៧៩៦–៥២ ចុះថ្ងៃទី ២៦–៧–៩៦ ស្តីពីប្រព័ន្ធ អប់រំចំនេះទូទៅ ១២ ឆ្នាំ

–បានពិនិត្យលិខិតស្នើសុំរបស់សមាគមមាតាបិតាសិក្សាសាលាបឋមសិក្សាក្បាលកោះសូទិនចុះថ្ងៃទី ០៤–១១–៩៦ និងចំណារឯកភាពរបស់ឯកឧត្តមអភិបាលខេត្តកំពង់ចាម លេខ ១៦៦៣ កច ចុះថ្ងៃទី ០៨–១១–៩៦

–តាមយោបល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម ប្តូរឈ្មោះសាលាបឋមសិក្សាក្បាលកោះសូទិន ស្ថិតនៅក្នុងឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម មកជាសាលាបឋមសិក្សា " ឈិត គីមយាត " ក្បាលកោះសូទិនវិញចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : លោកប្រធានមន្ទីរក្រសួងអប់រំយុវជន និងកីឡា លោកប្រធាននាយកដ្ឋានចាត់តាំង លោកប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច លោកប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាមលោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកកោះសូទិន លោកនាយកសាលាបឋមសិក្សា " ឈិត គីមយាត " ក្បាលកោះសូទិនមានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

តូច ឡេះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣៧ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា តាំងគោក មកជា

សាលាបឋមសិក្សា « សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ តាំងគោក »

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤

-បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត ០៧៩៦៥២ ចុះថ្ងៃទី ២៦-៧-៩៦ ស្តីពីប្រពន្ធ័យអប់រំ ចំនេះទូទៅ ១២ ឆ្នាំ ។

-បានឃើញលិខិតស្នើសុំ របស់សមាគមទ្រទ្រង់សាលា និងតំណាងមាតាបិតាសិស្ស ចុះថ្ងៃទី១៤-៨-៩៦ និងចំណារឯកភាពរបស់ឯកឧត្តមអភិបាលរងទី ១ ខេត្តកំពង់ធំ លេខ ៣៥៣ បជ ចុះថ្ងៃទី ២២-១០-៩៦

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ធំ ប្តូរឈ្មោះសាលាបឋមសិក្សាតាំងគោកដែលមានទីតាំងស្ថិតនៅឃុំ សូយោង ស្រុក បារាយណ៍ ខេត្តកំពង់ធំ មកជាសាលាបឋមសិក្សា សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ តាំងគោកវិញចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្ត កំពង់ធំ ប្រធានការិយាល័យអប់រំយុវជន

និង កីឡា ស្រុក បារាយណ៍ នាយកសាលាបឋមសិក្សា សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ តាំងពោក មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

តុល លាស

* * *

៦_ឯកសារក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ ២៥ ធក សសម

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤។
- បានឃើញអនុក្រឹត្យ លេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្ដីពីការ រៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា ។

- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយ សេវេនដេយអាត់វេនទីស្ទរបស់លោកជា ធារី ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។
- មានចំណារបញ្ជូន របស់ឯកឧត្តមអភិបាលខេត្ត លេខ ៧៥ រប ចុះថ្ងៃទី ១៥ មីនា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយសេវេនដេយអាត់វេនទីស្ទ នៃព្រះវិហារឈ្មោះ សេវេនដេយអាត់វេនទីស្ទ មួយ កន្លែង ដែលមានទីតាំងស្ថិតនៅក្រុមទី ១៩ ភូមិ សង់ឃ្លាំង ឃុំ តាំងក្រសាំង ស្រុក សន្ទុក ខេត្តកំពង់ធំ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស នៃព្រះវិហារឈ្មោះ សេវេនដេយ អាត់វេនទីស ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រីស ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ សេវេនដេយ អាត់វេនទីស្ទ ត្រូវគោរព និង អនុវត្តអោយបានត្រឹមត្រូវនិងម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវ ទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និងសាសនាខេត្តកំពង់ធំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ចៀង ធន្ធាត់

* * *

រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ២៦/៩៧ គធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

–បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។

–បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤។

–បានឃើញអនុក្រឹត្យ លេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា ។

–បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះត្រៃរត្ននិកាយសេវែនដេយ អាត់វេនទីស្ទ របស់លោក ប៉ែន ណារិទ្ធ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៦ ។

–មានចំណារបញ្ជូនរបស់ឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំង លេខ ១១៩០ សរសជ ចុះ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ។

សម្រេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយ សេវេនដេយអាត់វេនទីស នៃព្រះវិហារឈ្មោះ សេវេនដេយអាត់វេនទីស មួយកន្លែង ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៤៦៨ ផ្លូវជាតិ លេខ ៥ ឃុំ កំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទ នៃព្រះវិហារឈ្មោះ សេវេនដេយអាត់វេនទីស ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់លទ្ធិសាសនាគ្រីស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ សេវេនដេយ អាត់វេនទីស ត្រូវគោរព និងអនុវត្តអោយបានត្រឹមត្រូវនិងម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤: រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និងសាសនាខេត្តកំពង់ឆ្នាំង និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

[illegible]

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ២៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញអនុក្រឹត្យលេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តនិកាយ សេវេនដេយ អាត់វេនទីស្ទ របស់លោក សៅ គ្រុយ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦ ។
- មានចំណារបញ្ជូន របស់ឯកឧត្តមអភិបាលខេត្តតាកែវ លេខ ១៥២៩ លខបជ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តនិកាយសេវេនដេយអាត់វេនទីស្ទ នៃព្រះវិហារឈ្មោះ សេវេនដេយអាត់វេនទីស្ទ មួយកន្លែង ដែលមានទីតាំងស្ថិតនៅផ្ទះថ្មល់បែក ផ្លូវលេខ ៣១ ឃុំ រកាក្រៅ ស្រុក ដូនកែវ ខេត្តតាកែវ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទ នៃព្រះវិហារឈ្មោះ សេវេនដេយ អាត់វេនទីស្ទ ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់លទ្ធិសាសនាគ្រីស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ សេវេនដេយ អាត់វេនទីស្ទ ត្រូវគោរពនិងអនុវត្តអោយបានត្រឹមត្រូវនិងម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និងសាសនាខេត្តតាកែវ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ២៨ ៩៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ។

-បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤។

-បានឃើញអនុក្រឹត្យ លេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា ។

-បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយ សេវេនដេយ អាត់វេនទីស្ទ របស់លោក តុយ អូន ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

-មានចំណារបញ្ជូន របស់ឯកឧត្តមអភិបាលខេត្តតាកែវ លេខ ១៥២៨ លខបជ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយសេវេនដេយ អាត់វេនទីស្ទ នៃព្រះវិហារឈ្មោះ សេវេនដេយ អាត់វេនទីស្ទ មួយកន្លែង ដែលមានទីតាំងស្ថិតនៅភូមិ ជ្រោយប្រយ ឃុំ បារាយណ៍ ស្រុក ដូនកែវ ខេត្តតាកែវ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទ នៃព្រះវិហារឈ្មោះ សេវេនដេយ អាត់វេនទីស្ទ ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រីស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ សេវេនដេយ អាត់វេនទីស្ទ ត្រូវគោរពនិងអនុវត្តអោយបានត្រឹមត្រូវនិងម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធសន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និងសាសនាខេត្តតាកែវ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន ទណ្ណរ័ត្ន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៣៥/៩៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។

-បានឃើញអនុក្រឹត្យ លេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា ។

-បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះនៃសាសនា ខុងមឹង តាតាវ (ចិន) របស់លោក និង ឆឹង ឡុងសាន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ។

-លិខិតបញ្ជាក់ការយល់ព្រមរបស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ លេខ ១៨៦ លសស ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះ ខុងមឹង តាតាវ (ចិន) ព្រះវិហារនេះមានឈ្មោះហៅថា " ខុងមឹង តាតាវ " មានទីតាំងស្នាក់ការកណ្តាលស្ថិតនៅផ្ទះលេខ ១៥ D ផ្លូវលេខ១១៨ សង្កាត់ផ្សារដេប៉ូ ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ព្រះវិហារឈ្មោះ " ខុងមឹង តាតាវ " ត្រូវអនុញ្ញាតអោយប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់លទ្ធិសាសនាចិនខុងមឹងតាតាវ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ ខុងមឹង តាតាវ ត្រូវគោរពនិងអនុវត្តន៍អោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំ នៃព្រះវិហារ ខុងមឹងតាតាវ ត្រូវមានអ្នកទទួលខុសត្រូវចេះនិយាយ សរសេរអក្សរខ្មែរ ហើយត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : ប្រកាសលុបចោលសេចក្តីសំរេចលេខ ១៩៣/៩៤ កធស ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៤ ចេញដោយក្រសួងធម្មការ និង សាសនា ចាប់ពីពេលនេះតទៅ ។

ប្រការ ៥ : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៦ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៧ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារ័ត្ន

* * *

បោះពុម្ពនៅពេទ្យាពុម្ព និស្សិតភាគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល